# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៥៧ សហវ.ប្រក

ក្រសួងសាធារណការ និងដឹកជញ្ជូន

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការលក់ និងការដេញថ្លៃលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ

### ឧបនាយករដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ     រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៧/០០២ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៨ មាត្រា៤០ មាត្រា៤១ មាត្រា៤៧ មាត្រា៤៨ មាត្រា៧៥ មាត្រា៧៧ មាត្រា៨២ និងមាត្រា៩០ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១៥/០០១ ចុះថ្ងៃទី៩ ខែមករា ឆ្នាំ២០១៥

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia



ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ៧៣ អនក្រ.បក ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការចុះបញ្ជីផ្តល់បណ្ណសម្គាល់យានជំនិះ និងបំពាក់ផ្លាកលេខសម្គាល់យានជំនិះ
- យោងចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ អតីតនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១៦ លើលិខិតរួម ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន
- លិខិតលេខ០៥ សជណ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០២០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងចំណារដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៤ លើលិខិតរួម ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញប្រកាសលេខ១០១ សក.ប្រក.ដជគ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួង គ្រប់គ្រងការលក់លេខចុះបញ្ជីយានជំនិះ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ការលក់ និងការដេញថ្លៃលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ ស្ថិតក្រោមសមត្ថកិច្ចរបស់គណៈកម្មការអន្តរក្រសួង គ្រប់គ្រងការលក់លេខចុះបញ្ជីយានជំនិះ ហៅកាត់ថា "**គណៈកម្មការអន្តរក្រសួង**"។

**ប្រការ២ .-**

អនុញ្ញាតឱ្យអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន ប្រមូលចំណូលពីការលក់ និងការដេញថ្លៃលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ៣ .-**

លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ សំដៅដល់ប្រភេទលេខចុះបញ្ជីសម្រាប់រថយន្ត និងប្រភេទលេខចុះបញ្ជីសម្រាប់ទោចក្រយានយន្ត ត្រីចក្រយានយន្ត និងម៉ូតូកង់បួន ដែលផ្នែកខាងលើសរសេរអក្សរខ្មែរ "កម្ពុជា" ផ្នែកកណ្តាលជាលេខចុះបញ្ជីដែលមានលេខ ឬ/និងអក្សរឡាតាំង ឬ/និងសញ្ញាចុច(.) មិនលើសពី ៨(ប្រាំបី)ខ្ទង់ និងផ្នែកខាងក្រោមសរសេរអក្សរឡាតាំង "CAMBODIA" នៅពីក្រោមបន្ទាត់ផ្តេក។

**ប្រការ៤ .-**

អតិថិជនអាចស្វែងរកលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ នៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ ឬ អាចជ្រើសរើសលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនដោយខ្លួនឯង តាមរយៈបង្គុំលេខ ឬ/និងអក្សរឡាតាំង ឬ/និងសញ្ញាចុច(.) មិនលើសពី ៨(ប្រាំបី)ខ្ទង់ ដោយគោរពតាមលក្ខខណ្ឌដែលកំណត់ដូចខាងក្រោម ៖

១- លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួននីមួយៗត្រូវបានអនុញ្ញាតឱ្យប្រើសញ្ញាចុច(.)យ៉ាងច្រើនត្រឹម២(ពីរ)ប៉ុណ្ណោះ។ សញ្ញាចុច(.) នីមួយៗ ត្រូវស្ថិតនៅចន្លោះរវាងលេខ ឬ/និងអក្សរ ដោយមិនអនុញ្ញាតឱ្យប្រើសញ្ញាចុច(.) ចំនួន ២(ពីរ) ស្ថិតនៅជាប់គ្នាទេ។ លេខ ឬ អក្សរ ឬ សញ្ញាចុច(.) នីមួយៗ ត្រូវបានរាប់ជា ១(មួយ)ខ្ទង់។ លេខឬអក្សរដែលដូចគ្នា និងស្ថិតនៅជាប់ៗគ្នា ត្រូវបានអនុញ្ញាតឱ្យប្រើមិនលើសពី ៥(ប្រាំ)ខ្ទង់។ ឧទាហរណ៍: I.LOVE.U, 88888.88, AAAAABAA។

២- ការប្រើប្រាស់លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន ដែលពាក់ព័ន្ធនឹងឈ្មោះថ្នាក់ដឹកនាំជាន់ខ្ពស់ ជនល្បីឈ្មោះ និង លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនមួយចំនួនទៀតដែលមានលក្ខណៈរសើប ត្រូវស្នើសុំការសម្រេចពីគណៈកម្មការ អន្តរក្រសួង។

៣- លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនមួយចំនួន ត្រូវបានហាមឃាត់ រួមមាន ៖

- លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន ដែលទាក់ទងទៅនឹងឈ្មោះទីកន្លែងប្រវត្តិសាស្ត្រ ឈ្មោះប្រាសាទ ឈ្មោះ រាជធានី ខេត្ត ឈ្មោះក្រសួង ស្ថាប័ន គណបក្សនយោបាយ។
- លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន ដែលមានអត្ថន័យ ឬ សូរសព្ទ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ មាន ជាអាទិ៍ ការជេរប្រមាថ ការរើសអើង ការបៀតបៀនផ្លូវភេទ ឬ ប៉ះពាល់ដល់សីលធម៌ សុជីវធម៌ក្នុងសង្គម។

**ប្រការ៥ ._**

ការលក់លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ ត្រូវបានកំណត់ដូចខាងក្រោម ៖

១- ការលក់លេខចុះបញ្ជីសម្រាប់រថយន្ត

លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់រថយន្ត ដែលមានលេខ ឬ/និងអក្សរឡាតាំង ឬ/និងសញ្ញាចុច(.) ចាប់ពី ៤(បួន)ខ្ទង់ ដល់ ៨(ប្រាំបី)ខ្ទង់ ត្រូវបានកំណត់តម្លៃលក់ផ្អែកតាមមូលដ្ឋាន ឬ រូបមន្តគណនាតម្លៃ ដែល កំណត់ដោយគណៈកម្មការអន្តរក្រសួង លើកលែងតែ ៖

- ប្រភេទលេខចុះបញ្ជីដែលជាកម្មវត្ថុសម្រាប់ការដាក់ដេញថ្លៃជាសាធារណៈ
- ប្រភេទលេខចុះបញ្ជីដែលហាមឃាត់
- ប្រភេទលេខចុះបញ្ជីដែលបានលក់ចេញរួចហើយ។

២- ការលក់លេខចុះបញ្ជីសម្រាប់ទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួន

លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់ទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួន ដែលមាន លេខ ឬ/និងអក្សរឡាតាំង ឬ/និងសញ្ញាចុច(.) ចាប់ពី ១(មួយ)ខ្ទង់ ដល់ ៨(ប្រាំបី)ខ្ទង់ ត្រូវបានកំណត់តម្លៃលក់ ផ្អែកតាមមូលដ្ឋាន ឬ រូបមន្តគណនាតម្លៃ ដែលកំណត់ដោយគណៈកម្មការអន្តរក្រសួង លើកលែងតែ ៖

- ប្រភេទលេខចុះបញ្ជីដែលហាមឃាត់
- ប្រភេទលេខចុះបញ្ជីដែលបានលក់ចេញរួចហើយ។

គំនូសបំព្រួញស្តីពីដំណើរការនៃការលក់លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនតាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជី យានជំនិះ មានចែងក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៦ ._**

ការដាក់ដេញថ្លៃជាសាធារណៈនូវលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ ត្រូវបានអនុវត្តចំពោះ តែលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់រថយន្តតែប៉ុណ្ណោះ ដោយមិនអនុវត្តចំពោះលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន សម្រាប់ទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួន ទេ។

លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់រថយន្ត ដែលជាកម្មវត្ថុសម្រាប់ការដាក់ដេញថ្លៃជាសាធារណៈ រួមមាន លេខចុះបញ្ជីដែលមានលេខ ឬ/និងអក្សរឡាតាំង ឬ/និងសញ្ញាចុច(.) ចាប់ពី ១(មួយ)ខ្ទង់ ដល់ ៣(បី)ខ្ទង់ និងលេខចុះបញ្ជីមួយចំនួនផ្សេងទៀត ដែលមានលក្ខណៈពិសេស។ លេខចុះបញ្ជីដែលដាក់ដេញថ្លៃជាសាធារណៈ ត្រូវបានកំណត់តម្លៃមូលដ្ឋានសម្រាប់ការដេញថ្លៃឡើង ដែលសម្រេចដោយគណៈកម្មការអន្តរក្រសួង។

**ប្រការ៧.-**

ការកំណត់តម្លៃលក់ និងតម្លៃមូលដ្ឋានសម្រាប់ការដេញថ្លៃជាសាធារណៈ ត្រូវបានគិតគូរដោយផ្អែកលើកត្តាសំខាន់ៗមួយចំនួន ដូចខាងក្រោម ៖

- ចំនួនខ្ទង់កាន់តែតិច តម្លៃកាន់តែខ្ពស់
- ពាក្យពេចន៍នៅក្នុងវចនានុក្រមអង់គ្លេស
- លេខ 168
- លេខ ឬ អក្សរ ដូចគ្នា
- លេខ ឬ អក្សរ រៀងជាប់គ្នាតាមលំដាប់ឡើង
- លេខ ឬ អក្សរ រៀងជាប់គ្នាតាមលំដាប់ចុះ
- លេខ ឬ អក្សរមានលក្ខណៈឆ្លុះ
- លេខរៀងជាប់គ្នាជាចំនួនសេស ឬ គូ
- តួអក្សរនីមួយៗ។

**ប្រការ៨.-**

ការទិញលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ ត្រូវអនុវត្តតាមនីតិវិធីដូចតទៅ ៖

១- បំពេញបែបបទស្នើសុំទិញលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនតាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ ដែលមានអាសយដ្ឋាន https://vehicle.mpwt.gov.kh និងបំពេញព័ត៌មាន ដូចខាងក្រោម ៖
   - **ចំពោះជនជាតិខ្មែរ** : បំពេញឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត និងលេខអត្តសញ្ញាណប័ណ្ណ ព្រមទាំងលេខទូរសព្ទកំពុងប្រើប្រាស់របស់ម្ចាស់យានជំនិះ ដែលជាព័ត៌មានមូលដ្ឋានសម្រាប់ការចុះបញ្ជី ព្រមទាំងភ្ជាប់នូវឯកសារអត្តសញ្ញាណប័ណ្ណ។ ក្នុងករណីអាសយដ្ឋានអចិន្ត្រៃយ៍ ខុសពីអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណ ត្រូវភ្ជាប់មកជាមួយនូវសៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ។
   - **ចំពោះជនបរទេស** : បំពេញឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត លេខលិខិតឆ្លងដែន និងទិដ្ឋាការ ដែលមានសុពលភាព ព្រមទាំងលេខទូរសព្ទកំពុងប្រើប្រាស់របស់ម្ចាស់យានជំនិះ ដែលជាព័ត៌មានមូលដ្ឋាន សម្រាប់ការចុះបញ្ជី ព្រមទាំងភ្ជាប់នូវលិខិតបញ្ជាក់ទីលំនៅបច្ចុប្បន្ន។
   - **ចំពោះនីតិបុគ្គលឯកជន** : បំពេញនាមករណ៍ វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខបណ្ណពន្ធប៉ាតង់ និងលេខទូរសព្ទទំនាក់ទំនង ដែលជាព័ត៌មានមូលដ្ឋានសម្រាប់ការចុះបញ្ជី ព្រមទាំងភ្ជាប់មកជាមួយនូវវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងបណ្ណពន្ធប៉ាតង់ដែលមានសុពលភាព។

២- អតិថិជនអាចស្វែងរកទិញលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ ឬ ធ្វើលិខិតស្នើសុំមកគណៈកម្មការអន្តរក្រសួង ក្នុងករណីដែលលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួននោះពុំបានដាក់លក់នៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ។ នៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះមានបង្ហាញអំពីតម្លៃលក់ទៅតាមប្រភេទលេខនីមួយៗនៃលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ។

**ប្រការ៩ .-**

នីតិវិធីនៃការដេញថ្លៃលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់រថយន្ត ត្រូវបានកំណត់ដូចខាងក្រោម ៖

១- គណៈកម្មការអន្តរក្រសួង ត្រូវធ្វើសេចក្តីជូនដំណឹងជាសាធារណៈយ៉ាងតិច ១៥(ដប់ប្រាំ)ថ្ងៃ មុនកាលបរិច្ឆេទបើកដំណើរការដេញថ្លៃ។ ក្នុងសេចក្តីជូនដំណឹង ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីប្រភេទលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន និងតម្លៃមូលដ្ឋានសម្រាប់ការដេញថ្លៃឡើង រួមទាំងកាលបរិច្ឆេទ រយៈពេលដេញថ្លៃ ទីតាំងដាក់ឱ្យដេញថ្លៃ ឬ ធ្វើការដេញថ្លៃតាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ។ ករណីគ្មានអ្នកចូលរួមដេញថ្លៃ ត្រូវពន្យារពេលដេញថ្លៃដោយផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល ៧(ប្រាំពីរ)ថ្ងៃ ជាបន្តទៀត។

២- អតិថិជនដែលមានបំណងចូលរួមដេញថ្លៃ ត្រូវចុះឈ្មោះតាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ ដែលមានអាសយដ្ឋាន https://vehicle.mpwt.gov.kh ដោយត្រូវបំពេញតាមលក្ខខណ្ឌដូចតទៅ ៖

២.១- ការបំពេញព័ត៌មាន និងឯកសារភ្ជាប់ ៖

- **ចំពោះជនជាតិខ្មែរ** : បំពេញឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត និងលេខអត្តសញ្ញាណប័ណ្ណ ព្រមទាំងលេខទូរសព្ទកំពុងប្រើប្រាស់របស់ម្ចាស់រថយន្ត ដែលជាព័ត៌មានមូលដ្ឋានសម្រាប់ការចុះបញ្ជី ព្រមទាំងភ្ជាប់នូវឯកសារអត្តសញ្ញាណប័ណ្ណ។ ក្នុងករណីអាសយដ្ឋានអចិន្ត្រៃយ៍ ខុសពីអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណ ត្រូវភ្ជាប់មកជាមួយនូវសៀវភៅគ្រួសារ ឬ សៀវភៅស្នាក់នៅ។
- **ចំពោះជនបរទេស** : បំពេញឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត លេខលិខិតឆ្លងដែន និងទិដ្ឋាការ ដែលមានសុពលភាព ព្រមទាំងលេខទូរសព្ទកំពុងប្រើប្រាស់របស់ម្ចាស់រថយន្ត ដែលជាព័ត៌មានមូលដ្ឋាន សម្រាប់ការចុះបញ្ជី ព្រមទាំងភ្ជាប់នូវលិខិតបញ្ជាក់ទីលំនៅបច្ចុប្បន្ន។
- **ចំពោះនីតិបុគ្គលឯកជន** : បំពេញនាមករណ៍ វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខបណ្ណពន្ធប៉ាតង់ និងលេខទូរសព្ទទំនាក់ទំនង ដែលជាព័ត៌មានមូលដ្ឋានសម្រាប់ការចុះបញ្ជី ព្រមទាំងភ្ជាប់មកជាមួយនូវវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងបណ្ណពន្ធប៉ាតង់ដែលមានសុពលភាព។

២.២- អតិថិជនត្រូវបង់កម្រៃសិទ្ធិដេញថ្លៃ ដើម្បីទទួលបានការអនុញ្ញាតឱ្យចូលរួមដេញថ្លៃ។

២.៣- អតិថិជនត្រូវបំពេញព័ត៌មានអំពីហិរញ្ញវត្ថុរបស់ខ្លួននៅគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងគោរពតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម ៖

- មានគណនីនៅគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- ផ្ទៀងផ្ទាត់ភាពជាម្ចាស់គណនីរបស់បុគ្គលដែលចូលរួមដេញថ្លៃ និងតម្រូវឱ្យមានសមតុល្យទឹកប្រាក់សកម្មក្នុងគណនីយ៉ាងតិច ២០.០០០.០០០(ម្ភៃលាន)រៀល
- អ្នកដេញថ្លៃដែលបានឱ្យថ្លៃខ្ពស់លើសគេក្នុងអំឡុងពេលដេញថ្លៃកំពុងប្រព្រឹត្តទៅ មិនអាចបង្វែរទឹកប្រាក់ដែលបានបង្កកសម្រាប់ធានាការឱ្យថ្លៃ ចេញពីគណនីរបស់ខ្លួនបានទេ លុះណាតែមានបុគ្គលផ្សេងទៀតបានឱ្យថ្លៃខ្ពស់ជាង
- អ្នកឈ្នះការដេញថ្លៃត្រូវទូទាត់ប្រាក់បង្គ្រប់ ក្នុងរយៈពេលយ៉ាងយូរ ៦(ប្រាំមួយ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ចប់ការដេញថ្លៃ។ ក្នុងករណីអ្នកឈ្នះការដេញថ្លៃ មិនបានទូទាត់ប្រាក់បង្គ្រប់ក្នុងរយៈពេលកំណត់នេះ ត្រូវបានចាត់ទុកថា អ្នកឈ្នះការដេញថ្លៃ បានបោះបង់លេខចុះបញ្ជីរថយន្តដែលខ្លួនដេញថ្លៃបាន ហើយសមតុល្យទឹកប្រាក់សកម្មក្នុងគណនីរបស់អ្នកឈ្នះការដេញថ្លៃដែលបានបង្កកនោះ ត្រូវបានបង្វែរដើម្បីជាគុណប្រយោជន៍ដល់ចំណូលថវិកាជាតិ។

- ត្រូវអានឱ្យយល់ច្បាស់អំពីខ្លឹមសារ និងយល់ព្រមតាមលក្ខខណ្ឌតម្រូវផ្សេងទៀត ដែលបង្ហាញនៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ។

៣- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូ មានសិទ្ធិ ៖

- បង្កកសមតុល្យទឹកប្រាក់សកម្មក្នុងគណនីរបស់អ្នកដេញថ្លៃ ដែលឱ្យថ្លៃខ្ពស់ជាងគេ។
- លុបកំណត់ត្រាបង្កកទឹកប្រាក់ចេញពីបញ្ជីភ្លាមៗ ចំពោះអ្នកដេញថ្លៃដែលឱ្យថ្លៃទាប។

**ប្រការ១០ .-**

ការដេញថ្លៃលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់រថយន្ត ត្រូវធ្វើឡើងជាសាធារណៈ និងប្រព្រឹត្តទៅតាមវិធីពីរយ៉ាង ដូចខាងក្រោម ៖

**១- វិធីដេញថ្លៃតាមប្រព័ន្ធអនឡាញ**

១.១- អតិថិជនដែលមានបំណងចូលរួមដេញថ្លៃ ត្រូវចូលទៅកាន់ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ ដែលមានអាសយដ្ឋាន https://vehicle.mpwt.gov.kh។

១.២- ការប្រើប្រាស់ប្រព័ន្ធអនឡាញ តម្រូវឱ្យអ្នកដេញថ្លៃត្រូវចុះឈ្មោះ ឬចូលទៅកាន់ប្រព័ន្ធជាមុន ក្នុងករណីបើ ៖

- មិនទាន់មានគណនីប្រើប្រាស់ប្រព័ន្ធ : ត្រូវបង្កើតគណនីជាមុនសិន អនុលោមតាមលក្ខខណ្ឌតម្រូវក្នុងចំណុច ២.១ ប្រការ៩ នៃប្រកាសអន្តរក្រសួងនេះ
- មានគណនីប្រើប្រាស់ប្រព័ន្ធស្រាប់ : ចូលទៅកាន់ប្រព័ន្ធដោយប្រើប្រាស់លេខទូរសព្ទ ឬ អ៊ីម៉ែល។

១.៣- ជ្រើសរើសប្រភេទលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនណាមួយ ដែលត្រូវបានដាក់ឱ្យដេញថ្លៃ។

១.៤- បញ្ចូលព័ត៌មានគណនីហិរញ្ញវត្ថុ អនុលោមតាមលក្ខខណ្ឌតម្រូវក្នុងចំណុច ២.២ និង ២.៣ ប្រការ៩ នៃប្រកាសអន្តរក្រសួងនេះ។

១.៥- ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ នឹងធ្វើការផ្ទៀងផ្ទាត់ព័ត៌មានគណនីហិរញ្ញវត្ថុរបស់អ្នកដេញថ្លៃជាមួយនឹងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូ ដោយស្វ័យប្រវត្តិ។

១.៦- អ្នកចូលរួមដេញថ្លៃ ចាប់ធ្វើប្រតិបត្តិការឱ្យថ្លៃរហូតដល់ដំណើរការដេញថ្លៃត្រូវបានបិទបញ្ចប់ ដោយ ៖

- ត្រូវដាក់តម្លៃដេញថ្លៃរបស់ខ្លួន ដោយឱ្យថ្លៃខ្ពស់ជាងតម្លៃដេញថ្លៃរបស់បុគ្គលផ្សេងៗទៀត( ឱ្យថ្លៃខ្ពស់ជាងគេ )
- រាល់ពេលឱ្យថ្លៃម្តងៗ អ្នកដេញថ្លៃត្រូវប្រាកដថាគណនីហិរញ្ញវត្ថុរបស់ខ្លួន មានសមតុល្យទឹកប្រាក់សកម្មគ្រប់ចំនួនតាមលក្ខខណ្ឌតម្រូវក្នុងចំណុច ២.៣ ប្រការ៩ នៃប្រកាសអន្តរក្រសួងនេះ។

១.៧- ក្រោយពេលដំណើរការដេញថ្លៃត្រូវបានបិទបញ្ចប់ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូ រួមជាមួយនឹងក្រសួងសាធារណការ និងដឹកជញ្ជូន នឹងធ្វើការកាត់សមតុល្យទឹកប្រាក់សកម្មចេញពីគណនីរបស់អ្នកឈ្នះការដេញថ្លៃ ដោយអនុលោមតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងចំណុច ២.៣ ប្រការ៩ នៃប្រកាស-អន្តរក្រសួងនេះ។

១.៨- ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះនឹងបញ្ជូនសារ SMS ទៅអ្នកឈ្នះការដេញថ្លៃ ដែលរួមមាន ៖

- ព័ត៌មានលម្អិតស្តីពីកិច្ចប្រតិបត្តិការដេញថ្លៃ ដែលបានប្រព្រឹត្តទៅ
- បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់កម្រៃសិទ្ធិដេញថ្លៃ និងតម្លៃលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនដែលដេញថ្លៃបាន
- វិញ្ញាបនបត្របញ្ជាក់កម្មសិទ្ធិលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន ដែលមានសុពលភាព ៩០(កៅសិប)ថ្ងៃ ជារយៈពេលសម្រាប់សាមីខ្លួនធ្វើការស្នើសុំចុះបញ្ជីរថយន្ត និងបំពាក់ផ្លាកលេខ។

## ២- វិធីដេញថ្លៃតាមប្រព័ន្ធនៅក្នុងសាលដេញថ្លៃ

២.១- អតិថិជនដែលមានបំណងចូលរួមដេញថ្លៃ ត្រូវចូលទៅកាន់ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ ដែលមានអាសយដ្ឋាន https://vehicle.mpwt.gov.kh ឬ ធ្វើទំនាក់ទំនងផ្ទាល់ជាមួយមន្ត្រីទទួលបន្ទុករៀបចំការដេញថ្លៃ ដើម្បីបំពេញពាក្យស្នើសុំចូលរួមដេញថ្លៃ ដោយផ្តល់ព័ត៌មានអំពីអត្តសញ្ញាណផ្ទាល់ខ្លួន លេខគណនីហិរញ្ញវត្ថុ និងជ្រើសរើសលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនដែលត្រូវដេញថ្លៃ ដោយអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងចំណុច ២.១, ២.២ និង ២.៣ ប្រការ៩ នៃប្រកាសអន្តរក្រសួងនេះ។

២.២- មន្ត្រីទទួលបន្ទុករៀបចំការដេញថ្លៃ ត្រូវចេញសក្ខីបត្របញ្ជាក់ការអនុញ្ញាតឱ្យចូលរួមដេញថ្លៃ ជូនទៅអ្នកចូលរួមដេញថ្លៃ បន្ទាប់ពីអ្នកដេញថ្លៃបានបង់កម្រៃសិទ្ធិដេញថ្លៃទៅតាមតម្លៃដែលបានកំណត់។

២.៣- អ្នកដេញថ្លៃត្រូវធ្វើដំណើរទៅកាន់ទីតាំង ឬ សាលដេញថ្លៃ តាមកាលបរិច្ឆេទដែលកំណត់ដោយគណៈកម្មការអន្តរក្រសួង និងភ្ជាប់មកជាមួយនូវសក្ខីបត្របញ្ជាក់ការអនុញ្ញាតឱ្យចូលរួមដេញថ្លៃ និងឯកសារបញ្ជាក់អត្តសញ្ញាណផ្ទាល់ខ្លួន។

២.៤- អ្នកដេញថ្លៃត្រូវចូលទៅកាន់កៅអីអ្នកដេញថ្លៃ ដែលមានលេខសម្គាល់ដូចគ្នានឹងលេខសក្ខីបត្របញ្ជាក់ការអនុញ្ញាតឱ្យចូលរួមដេញថ្លៃ។

២.៥- ក្នុងពេលដេញថ្លៃ អ្នកដេញថ្លៃត្រូវធ្វើប្រតិបត្តិការឱ្យថ្លៃរហូតដល់ដំណើរការដេញថ្លៃត្រូវបានបិទបញ្ចប់ដោយ ៖

- ត្រូវដាក់តម្លៃដេញថ្លៃរបស់ខ្លួន ដោយឱ្យថ្លៃខ្ពស់ជាងតម្លៃដេញថ្លៃរបស់បុគ្គលផ្សេងៗទៀត( ឱ្យថ្លៃខ្ពស់ជាងគេ)
- រាល់ពេលឱ្យថ្លៃម្តងៗ អ្នកដេញថ្លៃត្រូវប្រាកដថាគណនីហិរញ្ញវត្ថុរបស់ខ្លួន មានសមតុល្យទឹកប្រាក់សកម្មគ្រប់ចំនួនតាមលក្ខខណ្ឌតម្រូវក្នុងចំណុច ២.៣ ប្រការ៩ នៃប្រកាសអន្តរក្រសួងនេះ។

២.៦- ក្រោយដំណើរការដេញថ្លៃត្រូវបានបិទបញ្ចប់ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដៃគូ រួមជាមួយនឹងក្រសួងសាធារណការ និងដឹកជញ្ជូន នឹងធ្វើការកាត់សមតុល្យទឹកប្រាក់សកម្មចេញពីគណនីរបស់អ្នកឈ្នះការដេញថ្លៃ ដោយអនុលោមតាមលក្ខខណ្ឌដែលបានកំណត់ក្នុងចំណុច ២.៣ ប្រការ៩ នៃប្រកាសអន្តរក្រសួងនេះ។

២.៧- អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក មានភារកិច្ចផ្តល់ព័ត៌មាន និងឯកសារជូនអ្នកឈ្នះការដេញថ្លៃ ដូចខាងក្រោម ៖

- ព័ត៌មានលម្អិតស្តីពីកិច្ចប្រតិបត្តិការដេញថ្លៃ ដែលបានប្រព្រឹត្តទៅ
- បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់កម្រៃសិទ្ធិដេញថ្លៃ និងតម្លៃលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនដែលដេញថ្លៃបាន
- វិញ្ញាបនបត្របញ្ជាក់កម្មសិទ្ធិលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន ដែលមានរយៈពេលសុពលភាព ៩០(កៅសិប) ថ្ងៃ សម្រាប់ការបំពេញបែបបទស្នើសុំចុះបញ្ជីរថយន្ត និងបំពាក់ផ្លាកលេខ។
- បញ្ជាក់ ៖ អ្នកឈ្នះការដេញថ្លៃនឹងទទួលបានព័ត៌មានតាមរយៈសារ SMS ដែលបញ្ជូនដោយប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ។

គំនូសបំព្រួញស្តីពីដំណើរការនៃការដាក់ដេញថ្លៃលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់រថយន្ត មានចែងក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ១១ .-**

ម្ចាស់កម្មសិទ្ធិលើលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន ត្រូវបំពេញបែបបទស្នើសុំចុះបញ្ជីយានជំនិះ ក្នុងរយៈពេលយ៉ាងយូរ ៩០(កៅសិប)ថ្ងៃ។ ក្នុងករណីម្ចាស់កម្មសិទ្ធិលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន មានការយឺតយ៉ាវ ឬ ខកខានមិនបានចុះបញ្ជីយានជំនិះក្នុងរយៈពេលកំណត់ ៩០(កៅសិប)ថ្ងៃ ត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាព និងបង់កម្រៃសេវាសាធារណៈតាមការកំណត់។

**ប្រការ១២ .-**

ការរក្សាទុកលេខចុះបញ្ជីសម្រាប់យានជំនិះ ត្រូវបានកំណត់ដូចខាងក្រោម ៖

១- ការរក្សាទុកលេខចុះបញ្ជីសម្រាប់រថយន្ត

ម្ចាស់រថយន្តមានសិទ្ធិស្នើសុំរក្សាទុកលេខចុះបញ្ជីរថយន្តរបស់ខ្លួនបាន ប៉ុន្តែការអនុញ្ញាតឱ្យរក្សាទុកលេខចុះបញ្ជីនេះអាចប្រព្រឹត្តទៅបានក្នុងលក្ខខណ្ឌដែលរថយន្តនោះ ត្រូវបានធ្វើបច្ចុប្បន្នភាពបំពាក់ផ្លាកលេខឱ្យបានចប់សព្វគ្រប់។ ចំពោះលេខចុះបញ្ជីរថយន្ត ដែលត្រូវបានអនុញ្ញាតឱ្យរក្សាទុក អាចយកទៅចុះបញ្ជីបំពាក់ផ្លាកលេខលើរថយន្តមួយទៀតបាន។

២- ការរក្សាទុកលេខចុះបញ្ជីសម្រាប់ទោចក្រយានយន្ត ត្រីចក្រយានយន្ត និងម៉ូតូកង់បួន

ម្ចាស់ទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួន មានសិទ្ធិស្នើសុំរក្សាទុកលេខចុះបញ្ជីរបស់ខ្លួនបាន ប៉ុន្តែការអនុញ្ញាតឱ្យរក្សាទុកលេខចុះបញ្ជីនេះអាចប្រព្រឹត្តទៅបានក្នុងលក្ខខណ្ឌដែលទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួននោះ ត្រូវបានធ្វើបច្ចុប្បន្នភាពបំពាក់ផ្លាកលេខនូវលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនឱ្យបានចប់សព្វគ្រប់។ ចំពោះលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនដែលត្រូវបានអនុញ្ញាតឱ្យរក្សាទុក អាចយកទៅចុះបញ្ជីបំពាក់ផ្លាកលេខលើទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួនមួយទៀតបាន។

៣- ម្ចាស់យានជំនិះ ដែលមានបំណងរក្សាទុកលេខចុះបញ្ជី និងចុះបញ្ជីបំពាក់ផ្លាកលេខយានជំនិះរបស់ខ្លួន ត្រូវមកបំពេញបែបបទស្នើសុំនៅអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកនៃក្រសួងសាធារណការ និងដឹកជញ្ជូន ឬនៅមណ្ឌលផ្តល់សេវាសាធារណៈរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

៤- ម្ចាស់យានជំនិះដែលទទួលបានការអនុញ្ញាតឱ្យរក្សាទុកលេខចុះបញ្ជី ត្រូវអនុវត្តតាមលក្ខខណ្ឌដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីយានជំនិះ ការផ្តល់ផ្លាកលេខសម្គាល់យានជំនិះ និងការលុបយានជំនិះចេញពីបញ្ជីយានជំនិះ។

**ប្រការ១៣ .-**

ការបង់កម្រៃសេវាសាធារណៈពាក់ព័ន្ធនឹងការចុះបញ្ជីលេខពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ ត្រូវអនុវត្តតាមតម្លៃសេវាសាធារណៈដែលចែងក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសអន្តរក្រសួងនេះ។ ចំណូលពីកម្រៃសេវាសាធារណៈនេះ ត្រូវកត់ត្រាជាចំណូលរបស់អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ១៤ .-**

ការចាត់ចែងបែងចែកប្រាក់ចំណូលដែលប្រមូលបានពីការលក់ និងការដេញថ្លៃលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ ត្រូវសម្រេចដោយគណៈកម្មការអន្តរក្រសួង ដែលប្រតិបត្តិតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

ចំពោះចំណូលប្រមូលបានពីសេវាសាធារណៈ ដែលចែងក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ចែងបែងចែកទៅតាមការកំណត់នៃប្រកាសអន្តរក្រសួងលេខ៨៦៣ សហវ.ប្រក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការកែសម្រួលអត្រាបែងចែកចំណូលពីសេវាសាធារណៈ ដែលប្រមូលបានដោយក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ១៥ .-**

ប្រកាសអន្តរក្រសួងលេខ១៤១១ សហវ.ប្រក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការលក់លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់រថយន្ត និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៦ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ... ខែ ... ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ប៉េង-ពោធិ៍នា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- អាជ្ញាធរសេវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ.១៥៧....... សហវ.ប្រក.អទច ចុះថ្ងៃទី.១៧... ខែ.មីនា... ឆ្នាំ២០២៥
ស្តីពីការលក់ និងការដេញថ្លៃលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ

# ដំណើរការនៃការលក់លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនតាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ



ឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងលេខ ១៥៧ សហវ.ប្រក.អទច ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២៥
ស្តីពីការលក់ និងការដេញថ្លៃលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ

# ដំណើរការនៃការដាក់ដេញថ្លៃលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់រថយន្ត



# គ. ដំណើរការដេញថ្លៃតាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ

**ចុះឈ្មោះដេញថ្លៃ**

**ចុះឈ្មោះដេញថ្លៃ**

- ជ្រើសរើសលេខដែលត្រូវបានដាក់ឱ្យដេញថ្លៃ
- បំពេញពាក្យចូលរួម និងបញ្ចូលព័ត៌មានគណនីហិរញ្ញវត្ថុ

**ដំណើរការដេញថ្លៃតាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ**

- បង់ប្រាក់កម្រៃសេវាសាធារណៈ
- ឱ្យថ្លៃខ្ពស់ជាងគេ

*សម្គាល់ទី១ ៖ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នឹងធ្វើការ ៖
- បង្កកប្រាក់ត្រូវធ្វើឡើងដោយស្វ័យប្រវត្តិ នៅក្នុងគណនីហិរញ្ញវត្ថុរបស់លោកអ្នក ក្រោមការឯកភាពពីម្ចាស់គណនី
- បង្វិលប្រាក់ដែលបានបង្កកជូនវិញភ្លាមៗ ដោយស្វ័យប្រវត្តិនៅពេលដែលអ្នកចូលរួមផ្សេងទៀត ឱ្យថ្លៃខ្ពស់ជាងលោកអ្នក

**ដំណើរការប្រព័ន្ធដោយស្វ័យប្រវត្តិ**

- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បង្កកប្រាក់ពីអ្នកឱ្យថ្លៃខ្ពស់ជាងគេបច្ចុប្បន្ន ដោយស្វ័យប្រវត្តិ
- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បង្វិលប្រាក់បង្កកជូនអ្នកឱ្យថ្លៃគ្រាមុន ដោយស្វ័យប្រវត្តិ

**ចុះឈ្មោះដេញថ្លៃ**

**បញ្ចប់ការដេញថ្លៃ**

- បញ្ចប់ដំណើរការដេញថ្លៃ
- គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទូទាត់ថ្លៃលេខពិសេសផ្ទាល់ខ្លួន ពីក្នុងគណនីអ្នកឈ្នះការដេញថ្លៃ
- ទទួលបានវិញ្ញាបនបត្របញ្ជាក់កម្មសិទ្ធលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន

*សម្គាល់ទី២ ៖ ប្រព័ន្ធនឹងបញ្ជូនសារ SMS ទៅអ្នកឈ្នះការដេញថ្លៃដោយភ្ជាប់ជាមួយនូវ ៖
- ព័ត៌មានប្រតិបត្តិការ
- បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់
- វិញ្ញាបនបត្របញ្ជាក់កម្មសិទ្ធលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន

*សម្គាល់ទី៣ ៖ ក្នុងករណីលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួននេះ មិនត្រូវបានចុះបញ្ជីជាមួយរថយន្ត ដែលជាកម្មសិទ្ធិរបស់លោកអ្នកក្នុងរយៈពេល ៩០ថ្ងៃ នោះលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួននេះ នឹងក្លាយជាកម្មសិទ្ធិរដ្ឋវិញដោយស្វ័យប្រវត្តិ ។

## ខ. ដំណើរការដេញថ្លៃក្នុងសាលដេញថ្លៃ

**មន្ត្រីសម្របសម្រួល**

**ចុះឈ្មោះដេញថ្លៃ**

### ចុះឈ្មោះដេញថ្លៃ

1. ទំនាក់ទំនងទៅកាន់មន្ត្រីអនុគណៈកម្មការ
2. ជ្រើសរើសលេខដែលត្រូវបានដាក់ឱ្យដេញថ្លៃ
3. បំពេញពាក្យចូលរួម និងបញ្ចូលព័ត៌មាន
4. ផ្តល់សក្ខីបត្របញ្ជាក់ការចូលរួមដេញថ្លៃ ទៅអ្នកដេញថ្លៃ

**ដំណើរការប្រព័ន្ធដោយស្វ័យប្រវត្តិ**

### ដំណើរការដេញថ្លៃតាមប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីយានជំនិះ

1. បង់ប្រាក់កម្រៃសេវាសាធារណៈ
2. ឱ្យថ្លៃខ្ពស់ជាងគេ

*សម្គាល់ទី១ ៖ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ នឹងធ្វើការ ៖
- បង្កកប្រាក់ត្រូវធ្វើឡើងដោយស្វ័យប្រវត្តិ នៅក្នុងគណនីហិរញ្ញវត្ថុរបស់លោកអ្នក ក្រោមការឯកភាពពីម្ចាស់គណនី
- បង្វិលប្រាក់ដែលបានបង្កកជូនវិញភ្លាមៗ ដោយស្វ័យប្រវត្តិនៅពេលដែលអ្នកចូលរួមផ្សេងទៀត ឱ្យថ្លៃខ្ពស់ជាងលោកអ្នក

3. គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បង្កកប្រាក់ពីអ្នកឱ្យថ្លៃខ្ពស់ជាងគេបច្ចុប្បន្ន ដោយស្វ័យប្រវត្តិ
4. គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បង្វិលប្រាក់បង្កកជូនអ្នកឱ្យថ្លៃគ្រាមុន ដោយស្វ័យប្រវត្តិ

(ត្រឡប់ទៅ "ឱ្យថ្លៃខ្ពស់ជាងគេ")

**មន្ត្រីសម្របសម្រួល**

**ចុះឈ្មោះដេញថ្លៃ**

### បញ្ចប់ការដេញថ្លៃ

1. បញ្ចប់ដំណើរការដេញថ្លៃ
2. គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទូទាត់ថ្លៃលេខពិសេសផ្ទាល់ខ្លួន ពីក្នុងគណនីអ្នកឈ្នះការដេញថ្លៃ
3. ទទួលបានវិញ្ញាបនបត្របញ្ជាក់កម្មសិទ្ធលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន

*សម្គាល់ទី២ ៖ ប្រព័ន្ធនឹងបញ្ជូនសារ SMS ទៅអ្នកឈ្នះការដេញថ្លៃដោយភ្ជាប់ជាមួយនូវ៖
- ព័ត៌មានប្រតិបត្តិការ
- បង្កាន់ដៃបញ្ជាក់ការបង់ប្រាក់
- វិញ្ញាបនបត្របញ្ជាក់កម្មសិទ្ធលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន

*សម្គាល់ទី៣ ៖ ក្នុងករណីលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួននេះ មិនត្រូវបានចុះបញ្ជីជាមួយរថយន្ត ដែលជាកម្មសិទ្ធិរបស់លោកអ្នកក្នុងរយៈពេល ៩០ថ្ងៃ នោះលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួននេះ នឹងក្លាយជាកម្មសិទ្ធិរដ្ឋវិញដោយស្វ័យប្រវត្តិ។

ឧបសម្ព័ន្ធទី៣ នៃប្រកាសអន្តរក្រសួងលេខ ០៩៧ សហវ.ប្រក.អទច ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២៥ ស្តីពីការលក់ និងការដេញថ្លៃលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ

## តម្រូវសេវាសាធារណៈពាក់ព័ន្ធនឹងការចុះបញ្ជីលេខពិសេសផ្ទាល់ខ្លួនសម្រាប់យានជំនិះ

| លេខរៀងចំនួនសេវា | | បរិយាយ | តម្លៃឯកតានៃសេវា (រៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | ក- | ការចុះបញ្ជីយានជំនិះ ដែលបំពាក់លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន | | | |
| ១ | ១ | ការចុះបញ្ជីទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួន | ១២០ ០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ២ | ២ | ការចុះបញ្ជីទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួន សម្រាប់នីតិបុគ្គលឯកជន ឬ សហកម្មសិទ្ធិ | ១៥០ ០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៣ | ៣ | ការចុះបញ្ជីរថយន្ត | ៥០០ ០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ៤ | ៤ | ការចុះបញ្ជីរថយន្ត សម្រាប់នីតិបុគ្គលឯកជន ឬ សហកម្មសិទ្ធិ | ៧០០ ០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ |
| | ខ- | ការផ្ទេរកម្មសិទ្ធិយានជំនិះ ដែលបំពាក់លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន | | | |
| ៥ | ១ | ការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួន | ៤០ ០០០ | ១០ថ្ងៃ | អចិន្ត្រៃយ៍ |
| ៦ | ២ | ការផ្ទេរកម្មសិទ្ធិទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួន ដោយប្តូរលេខចុះបញ្ជីថ្មី | ១០០ ០០០ | ១០ថ្ងៃ | អចិន្ត្រៃយ៍ |
| ៧ | ៣ | ការផ្ទេរកម្មសិទ្ធិរថយន្ត | ៦០ ០០០ | ១០ថ្ងៃ | អចិន្ត្រៃយ៍ |
| ៨ | ៤ | ការផ្ទេរកម្មសិទ្ធិរថយន្ត ដោយប្តូរលេខចុះបញ្ជីថ្មី | ៣០០ ០០០ | ១០ថ្ងៃ | អចិន្ត្រៃយ៍ |
| | គ- | ការប្តូរ ទុតិយតា តតិយតា បណ្ណ និងផ្លាកលេខ ចំពោះយានជំនិះ ដែលបំពាក់លេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន | | | |
| ៩ | ១ | បណ្ណសម្គាល់ទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួន | ៤០ ០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ១០ | ២ | បណ្ណសម្គាល់រថយន្ត | ៦០ ០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ១១ | ៣ | ផ្លាកលេខសម្គាល់ទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួន | ៦០ ០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ១២ | ៤ | ផ្លាកលេខរថយន្តម្ខាង | ១២០ ០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៣ | ៥ | ផ្លាកលេខរថយន្ត១គូ | ២៤០ ០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ |

| លេខរៀង ចំនួនសេវា | | បរិយាយ | តម្លៃឯកតា នៃសេវា (រៀល) | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| | ឃ- | ការរក្សាទុក និងការបន្តសុពលភាពលេខចុះបញ្ជីពិសេសផ្ទាល់ខ្លួន | | | |
| ១៤ | ១ | ការរក្សាទុកលេខចុះបញ្ជីទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួន | ២០០ ០០០ | ៥ថ្ងៃ | ៩០ថ្ងៃ |
| ១៥ | ២ | ការរក្សាទុកលេខចុះបញ្ជីរថយន្ត | ៤ ០០០ ០០០ | ៥ថ្ងៃ | ៩០ថ្ងៃ |
| ១៦ | ៣ | ការរក្សាទុកលេខចុះបញ្ជីទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួន សម្រាប់ការធ្វើមរតក | ៨០ ០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៧ | ៤ | ការរក្សាទុកលេខចុះបញ្ជីរថយន្ត សម្រាប់ការធ្វើមរតក | ៥០០ ០០០ | ៥ថ្ងៃ | អចិន្ត្រៃយ៍ |
| ១៨ | ៥ | ការបន្តសុពលភាពលេខចុះបញ្ជីទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួន | ៨០ ០០០ | ៥ថ្ងៃ | ៩០ថ្ងៃ |
| ១៩ | ៦ | ការបន្តសុពលភាពលេខចុះបញ្ជីរថយន្ត | ៥០០ ០០០ | ៥ថ្ងៃ | ៩០ថ្ងៃ |
| | ង- | ការរក្សាទុកលេខចុះបញ្ជីរាជធានី ខេត្ត | | | |
| ២០ | ១ | ការរក្សាទុកលេខចុះបញ្ជីទោចក្រយានយន្ត ឬ ត្រីចក្រយានយន្ត ឬ ម៉ូតូកង់បួន | ១ ០០០ ០០០ | ៥ថ្ងៃ | ៩០ថ្ងៃ |
| ២១ | ២ | ការរក្សាទុកលេខចុះបញ្ជីរថយន្ត | ៦ ០០០ ០០០ | ៥ថ្ងៃ | ៩០ថ្ងៃ |
| | ច- | ការផ្តល់សិទ្ធិចូលរួមដេញថ្លៃលេខចុះបញ្ជីលេខពិសេសផ្ទាល់ខ្លួនសម្រាប់រថយន្ត | | | |
| ២២ | ១ | សិទ្ធិចូលរួមដេញថ្លៃ | ៥០ ០០០ | ភ្លាមៗ | ១លើក |